

# វ៉ាក់សាំង COVID-19
# អ្វីដែលយុវវ័យត្រូវដឹង

## តើខ្ញុំអាចទទួលបានវ៉ាក់សាំងបង្ការជំងឺ COVID-19 បានដែរឬទេ?




**ប្រសិនបើអ្នកមានអាយុ 12 ឆ្នាំ ឬលើសពីនេះ អ្នកអាចចាក់វ៉ាក់សាំង Pfizer បាន។**

- វ៉ាក់សាំងគឺ**ឥតគិតថ្លៃ**សម្រាប់មនុស្សគ្រប់គ្នា។
- អ្នកមិនចាំបាច់មានការធានារ៉ាប់រងទេ។
- អ្នកនឹងមិនត្រូវបានសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។
- ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំអ្នកនឹងត្រូវមានការយល់ព្រមពីឪពុកម្តាយឬអាណាព្យាបាលស្របច្បាប់ដើម្បីទទួលបានការចាក់វ៉ាក់សាំង។

## មូលហេតុដែលត្រូវចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19



- វ៉ាក់សាំងបង្ការជំងឺ COVID-19 **មានសុវត្ថិភាព និងមានប្រសិទ្ធភាព**។
- មនុស្សវ័យក្មេងភាគច្រើនដែលបានកើតជំងឺ COVID-19 មានរោគសញ្ញាស្រាល ឬគ្មានរោគសញ្ញា ប៉ុន្តែមនុស្សខ្លះអាចឈឺខ្លាំង ឬមានបញ្ហាសុខភាពយូរអង្វែង។
- ប្រសិនបើអ្នកឆ្លងជំងឺ COVID-19 អ្នកអាចចម្លងវីរុសនេះទៅកាន់អ្នកដទៃ ទោះបីជាអ្នកមិនមានអារម្មណ៍ថាឈឺក៏ដោយ។ ជួយការពារមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកដោយទទួលថ្នាំបង្ការ។



## តើខ្ញុំអាចទទួលវ៉ាក់សាំងនៅទីណា?

សួរវេជ្ជបណ្ឌិតរបស់អ្នក ឱសថស្ថានក្នុងតំបន់ ឬចូលទៅកាន់គេហទំព័រ **VaccinateLACounty.com** ដើម្បីស្វែងរកទីតាំងចាក់វ៉ាក់សាំងដែលនៅជិតអ្នក។ រកមើលគ្លីនិកចាក់វ៉ាក់សាំងមាននៅតាមសាលារបស់អ្នក ឬក្នុងសង្កាត់របស់អ្នក។ **មិនចាំបាច់ណាត់ជួបទេ**នៅតាមទីតាំងច្រើន។

សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលចាក់វ៉ាក់សាំង DPH តាមរយៈលេខ **833-540-0473** ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្វែងរកវ៉ាក់សាំង ត្រូវការការដឹកជញ្ជូនទៅទីតាំងចាក់វ៉ាក់សាំង ឬស្នើសុំការចាក់វ៉ាក់សាំងនៅក្នុងផ្ទះប្រសិនបើអ្នកនៅផ្ទះ។ បើកបម្រើការជូនជារៀងរាល់ថ្ងៃចាប់ពីម៉ោង 8:00ព្រឹក ដល់ម៉ោង 8:30យប់។

ព័ត៌មានមានជាច្រើនភាសាដោយបម្រើការ 24/7 ដោយទូរស័ព្ទទៅកាន់ 2-1-1។

## តើមានផលប៉ះពាល់អ្វីខ្លះ?

- ផលប៉ះពាល់គឺជារឿងធម្មតា ហើយជាសញ្ញាបង្ហាញថាប្រព័ន្ធភាពស៊ាំរបស់អ្នកគឺ **កំពុងបង្កើតការការពារ**។
- ផលប៉ះពាល់នោះរួមមានទាំង ការឈឺដៃ ឬឡើងក្រហម មានអារម្មណ៍នឿយហត់ គ្រុនក្តៅ រងាញាក់ ឈឺក្បាល ឬឈឺសាច់ដុំ។ មិនមែនមនុស្សគ្រប់គ្នានឹងទទួលមានផលប៉ះពាល់ទាំងនេះទេ។
- ពួកគេអាចនឹងពិបាកធ្វើសកម្មភាពប្រចាំថ្ងៃខ្លះៗ ប៉ុន្តែគួរតែតមការធ្វើសកម្មភាពទាំងនោះក្នុងរយៈពេលពីរបីថ្ងៃ។



**VaccinateLACounty.com**
**(Cambodian)**

County of Los Angeles Public Health

6-3-21

# វ៉ាក់សាំង COVID-19
# អ្វីដែលយុវវ័យត្រូវដឹង

## តើវ៉ាក់សាំងបង្ការជំងឺ COVID-19 មានសុវត្ថិភាពដែរឬទេ?



- អ្នកមិនអាចមានជំងឺCOVID-19ពីវ៉ាក់សាំងនេះទេ។ គ្មានវ៉ាក់សាំងណាមួយមានផ្ទុកវីរុសដែលបង្កឱ្យមានជំងឺCOVID-19នោះទេ។
- វ៉ាក់សាំងទាំងនេះត្រូវបានធ្វើតេស្តលើមនុស្សរាប់ម៉ឺននាក់រួមមានមនុស្សគ្រប់កម្រិតអាយុ មនុស្សដែលមានពណ៌សម្បុរផ្សេងៗ និងមនុស្សដែលមានបញ្ហាសុខភាព ហើយរកឃើញថាគឺមានសុវត្ថិភាព។
- គ្រប់ជំហានគឺទាមទារឱ្យមានភាពប្រាកដប្រជាដើម្បីធ្វើឱ្យវ៉ាក់សាំងមាន **សុវត្ថិភាព និងប្រសិទ្ធិភាព**។



- មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថាវ៉ាក់សាំងបង្ការជំងឺ COVID-19 ជះឥទ្ធិពលដល់ការវិវត្តរបស់មនុស្សវ័យជំទង់ ឬសមត្ថភាពរបស់អ្នកក្នុងការមានកូននោះទេ។ ការទទួលការចាក់វ៉ាក់សាំងនឹងបន្ថយឱកាសរបស់អ្នកក្នុងការឈឺ ឆ្លងទៅអ្នកដទៃ ការសម្រាកនៅមន្ទីរពេទ្យ ឬស្លាប់ដោយសារជំងឺ COVID-19។








## មុនពេលអ្នកចាក់វ៉ាក់សាំង

- ពិភាក្សាជាមួយឪពុកម្តាយរបស់អ្នកអំពីវ៉ាក់សាំងបង្ការជំងឺ COVID-19។ សួរពួកគេនូវសំណួរណាដែលអ្នកអាចមាន។
- ត្រូវប្រាកដថាគ្លីនិកផ្តល់វ៉ាក់សាំងដែលអ្នកនឹងទៅចាក់គឺមានវ៉ាក់សាំង Pfizer។
- យកឯកសារដែលបង្ហាញពីថ្ងៃខែឆ្នាំកំណើតរបស់អ្នកក្នុងករណីដែលអ្នកត្រូវបានស្នើសុំឱ្យបង្ហាញពីភស្តុតាងនៃអាយុ។
- កុំភ្លេចពី**ទម្រង់ព្រមព្រៀងរបស់ឪពុកម្តាយ**។ ឪពុកម្តាយរបស់អ្នក ឬ អាណាព្យាបាលស្របច្បាប់នឹងត្រូវបំពេញបែបបទយល់ព្រម។
- ទទួលព័ត៌មានអំពីវ៉ាក់សាំងផ្សេងទៀត។ វ៉ាក់សាំងបង្ការជំងឺ COVID-19 អាចត្រូវបានផ្តល់ឱ្យក្នុងពេលតំណាលគ្នា មុនពេល ឬ ក្រោយពេលចាក់វ៉ាក់សាំងផ្សេងទៀតដូចជា HPV ដែរ ។

## បន្ទាប់ពីអ្នកបានចាក់វ៉ាក់សាំងពេញលេញហើយ



- អ្នកត្រូវបាន**ចាក់វ៉ាក់សាំងពេញលេញ**គឺ 2 សប្តាហ៍បន្ទាប់ពីអ្នកទទួលបានវ៉ាក់សាំង Pfizer លើកទី2។ វាត្រូវការពេលវេលាសម្រាប់រាងកាយរបស់អ្នកដើម្បីបង្កើតភាពស៊ាំ ។
- នៅពេលដែលអ្នកចាក់វ៉ាក់សាំងពេញលេញហើយ៖
  - អាចចាប់ផ្តើមធ្វើសកម្មភាពដែលអ្នកមិនអាចធ្វើបាន - ដូចជាដើរលេងជាមួយមិត្តភក្តិ ការលេងកីឡា (ដោយមិនចាំបាច់ធ្វើតេស្តរកមេរោគ) ឬទៅលេងគ្រួសារ។
  - មិនចាំបាច់ធ្វើចត្តាឡីស័ក (ដាក់ឱ្យនៅដាច់ដោយឡែក) ទេ ប្រសិនបើមិត្តភក្តិ សមាជិកគ្រួសារ គ្រូ ឬមិត្តរួមក្រុមឆ្លងជំងឺ COVID-19។



**VaccinateLACounty.com**
**(Cambodian)**

County of Los Angeles Public Health